

ចេញពីបណ្តាសាទៅឯព្រះពរ



From Curse To Blessing
ដោយ ដេរេក ព្រីនស៍

រីករាយណាស់ដែលបានមកជួបលោកអ្នកជាថ្មី នៅពេលដែលយើងបន្តប្រធានបទរបស់យើងនៅសប្តាហ៍ នេះតទៅទៀតគឺ៖ ចេញពីបណ្តាសាមកឯព្រះពរ។ ខ្ញុំទុកចិត្តថា ប្រធានបទនេះ ពិតជាមានប្រយោជន៍សម្រាប់ លោកអ្នក។

ប៉ុន្តែជាបឋម ខ្ញុំសូមនិយាយថា «សូមអរគុណ» ចំពោះបងប្អូនទាំងអស់ដែលបានសរសេរសំបុត្រមកកាន់ខ្ញុំ។ មុននឹងបញ្ចប់ការអធិប្បាយនេះ យើងនឹងផ្តល់ជូនបងប្អូននូវអាសយដ្ឋានសម្រាប់ផ្ញើសំបុត្រមកកាន់យើងខ្ញុំ។សូមបងប្អូនកុំស្ទាក់ស្ទើរក្នុងការចែករំលែកជាមួយយើងខ្ញុំអំពីតម្រូវការផ្ទាល់ខ្លួន បញ្ហាដែលបងប្អូនកំពុងជួបប្រទះ និងសំណូមពរអធិស្ឋានរបស់បងប្អូន។ ជារៀងរាល់ខែ មានអ្នកស្តាប់កម្មវិធីរបស់យើងខ្ញុំជាច្រើនបានសរសេរមក ដើម្បីប្រាប់អំពីសំណូមពរអធិស្ឋានរបស់ពួកគេ ដែលព្រះបានឆ្លើយតបយ៉ាងអស្ចារ្យ។

ឥឡូវនេះ យើងនឹងត្រឡប់មកកាន់ប្រធានបទរបស់យើង « ចេញពីបណ្តាសាមកឯព្រះពរ»។

ថ្ងៃនេះ ខ្ញុំនឹងពន្យល់តាមពាក្យដ៏ជាក់ច្បាស់ អំពីរបៀបដែលលោកអ្នកអាចចេញពីបណ្តាសាមកឯព្រះ ពរ។ ប៉ុន្តែ មុនដំបូង ខ្ញុំសូមរំឭកឡើងវិញនូវចំណុចសំខាន់ៗមួយចំនួន ដែលខ្ញុំបាននិយាយនៅក្នុងមេរៀនមុន។ ជាបឋម ខ្ញុំសូមរំឭកលោកអ្នកអំពីសញ្ញាសម្គាល់ទូទៅដែលប្រាប់ថា ប្រហែលជាមានបណ្តាសាលើជីវិតរបស់លោកអ្នក។

ទីមួយ និយាយជាទូទៅ បណ្តាសាប្រៀបបីដូចជាស្រមោលខ្មៅងងឹត ឬដៃអាក្រក់ដែលសន្លឹងមកលើ លោកអ្នក តាំងពីអតីតកាលតមក ហើយលោកអ្នកមិនអាចរួចផុតពីស្រមោលខ្មៅងងឹតនោះបាន។

បន្ទាប់មក ខ្ញុំបានរៀបរាប់សញ្ញាសម្គាល់ជាក់លាក់ប្រាំពីរ។ ខ្ញុំសូមសង្ខេបឡើងវិញបន្តិច។ សញ្ញា សម្គាល់ទាំងនោះសំខាន់ណាស់ ដែលលោកអ្នកត្រូវដឹង។

ទីមួយ: ការវង្វេងស្មារតី ឬបញ្ហាផ្លូវចិត្ត។

ទីពីរ: ជំងឺរ៉ាំរ៉ៃ ឬកើតឡើងម្តងហើយម្តងទៀត ជាពិសេសជំងឺតំណពូជ ឬគ្មានការវិភាគច្បាស់ លាស់ខាងវេជ្ជសាស្ត្រ។

ទីបី: រលូតកូនម្តងហើយម្តងទៀត ឬបញ្ហាទាក់ទងនឹងស្ត្រី។

ទីបួន: ការបែកបាក់អាពាហ៍ពិពាហ៍ និងការបែកបាក់គ្រួសារ។

ទីប្រាំ: ឱនភាពហិរញ្ញវត្ថុរហូត ជាពិសេសនៅពេលដែលចំណូលហាក់បីដូចជាគ្រប់ត្រាន់។

ទីប្រាំមួយ: ចេះតែមានគ្រោះថ្នាក់រហូត។

និង ទីប្រាំពីរ: នៅក្នុងគ្រួសារ មានប្រវត្តិធ្វើអត្តឃាត ឬស្លាប់ខុសប្រក្រតី។

បន្ទាប់មកខ្ញុំ ក៏បានប្រាប់អំពីប្រភព ឬបុព្វហេតុទូទៅជាច្រើនដែលនាំឲ្យមានបណ្តាសា ដោយនឹកចាំពីអ្វី ដែលបទគម្ពីរប្រាប់: បណ្តាសាមិនមែនចូលមកដោយឥតហេតុនោះទេ។ បន្ទាប់មក ខ្ញុំបានរៀបរាប់ប្រភព ឬ បុព្វហេតុដែលនាំឲ្យមានបណ្តាសា ប្រហែលជាដប់ពីរ:

ទីមួយ: ការថ្វាយបង្គំរូបព្រះ ព្រះក្លែងក្លាយ និងមន្តអាគមន៍។

ទីពីរ: ការមិនគោរពឪពុកម្តាយ។

ទីបី: ការរួមដំណេកខុសច្បាប់ ឬខុសពីលក្ខណៈធម្មជាតិ។

ទីបួន អំពើអយុត្តិធម៌ចំពោះអ្នកទន់ខ្សោយ ឬអ្នកគ្មានទីពឹង ហើយឧទាហរណ៍យ៉ាងល្អបំផុតអំពីការ នោះនៅក្នុងសង្គមរបស់យើងសព្វថ្ងៃ ពីការរំលូតកូនដោយចេតនា។

ទីប្រាំ: ការពឹងផ្អែកលើការខំប្រឹងប្រែងខាងសាច់ឈាម។

ទីប្រាំមួយ: ការលួច ឬការបោកបញ្ឆោត។

ទីប្រាំពីរៈ ការកំណាញ់ជាមួយព្រះ។

ទីប្រាំបី: ពាក្យសម្តីដែលអ្នកមានសិទ្ធិអំណាចនៅក្នុងទំនាក់ទំនងនិយាយ ដូចជាប្តី ឪពុកម្តាយ ឬគ្រូជា ដើម។

ទីប្រាំបួន: បណ្តាសាដាក់ដោយខ្លួនឯង ជាបណ្តាសាដែលមនុស្សដាក់មកលើខ្លួនឯង។

ទីដប់: ពាក្យសម្តីដែលមនុស្សតំណាងឲ្យអារក្សសាតាំងនិយាយ មានដូចជាគ្រូមន្តអាគមជាដើម។

ទីដប់មួយ: ការអធិស្ឋានតាមអារម្មណ៍ ចេះតែបញ្ចេញសម្តី ការនិយាយដើម គឺនិយាយដោយមាន ឥរិយាបថខុសឆ្គង។

ទីដប់ពីរៈ ការតាំងសញ្ញាមិនស្របតាមបទគម្ពីរ គឺការរួមគ្នាដោយតាំងសញ្ញាជាមួយមនុស្សដែលបម្រើឲ្យ អំណាចនៃវិញ្ញាណអាក្រក់ ហើយវង្វេងចេញពីព្រះ។ ខ្ញុំបានជូនឧទាហរណ៍ដ៏ជាក់លាក់មួយអំពីក្រុមបងប្អូន។

ថ្ងៃនេះ ខ្ញុំនឹងប្រាប់លោកអ្នកពីរបៀចេញពីបណ្តាសាទៅឯព្រះពរ។ ខ្ញុំនឹងនិយាយដោយប្រើពាក្យ ដែលសាមញ្ញ ច្បាស់ និងជាក់លាក់ ហើយខ្ញុំក៏ចង់ឲ្យលោកអ្នកស្តាប់ដោយប្រុងប្រយ័ត្ន។ ទីមួយ មូលដ្ឋានគ្រឹះ នៃការប្រោសលោះទាំងអស់ចេញពីបណ្តាសា គឺជាតង្វាយលោះបាបរបស់ព្រះយេស៊ូវ។ ការនេះបានប្រាប់យ៉ាង ច្បាស់នៅក្នុងកាឡាទី ៣:១៣-១៤ ជាខគម្ពីរគន្លឹះសម្រាប់ប្រធានបទនេះទាំងមូល។

> «ព្រះគ្រីស្ទបានលោះយើងឲ្យរួចពីបណ្តាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រឡប់ជាត្រូវបណ្តាសាជំនួស យើង (ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវបណ្តាសាហើយអ្នកណាដែលត្រូវគេព្យួរនៅលើឈើ») ដើម្បីឲ្យពររបស់លោកអ័ប្រាហាំ ក្នុងព្រះគ្រីស្ទយេស៊ូវបានទៅដល់សាសន៍ដទៃ...»។

មានការផ្លាស់ប្តូរចេញពីបណ្តាសាមកឯព្រះពរ ដែលបានធ្វើឲ្យកើតឡើង ដោយព្រោះនៅលើឈើឆ្កាង ព្រះយេស៊ូវបានត្រឡប់ជាត្រូវបណ្តាសា ដែលជាបណ្តាសាសម្រាប់យើង ដើម្បីប្តូរមកវិញឲ្យយើងបានទទួលព្រះពរ សម្រាប់ការស្តាប់បង្គាប់របស់ព្រះអង្គដែលគ្មានបាប។ ការនេះត្រូវបានបញ្ជាក់ប្រាប់ជាទូទៅ នៅក្នុងគម្ពីរអេសាយ ៥៣:៦:

> «យើងទាំងអស់គ្នាបានវង្វេងចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបានទម្លាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើព្រះអង្គ (គឺព្រះយេស៊ូវ)»។

ពាក្យ «អំពើទុច្ចរិត» មិនត្រឹមតែមានន័យថាជាការបះបោរប៉ុណ្ណោះទេ ថែមទាំងមានន័យថា ជាផលអាក្រក់ទាំងអស់របស់ការបះបោរ ហើយផលអាក្រក់មួយក្នុងចំណោមនោះ គឺជាបណ្តាសាដែលកើតចេញពីការមិនស្តាប់ និងមិនធ្វើតាមព្រះសូរសៀងរបស់ព្រះ។

កាលបើលោកអ្នកបានបំពេញលក្ខខណ្ឌទាំងនេះ ហើយប្រកាសយកការប្រោសលោះរបស់លោកអ្នក ខ្ញុំចង់រំឭកលោកអ្នកយ៉ាងមុតមាំថា ព្រះទ្រង់នៅតែទាមទារឲ្យមានការស្តាប់បង្គាប់។ ខ្ញុំសូមរំឭកលោកអ្នកចេញពីពាក្យរបស់លោកម៉ូសេ នៅក្នុងចោទិយកថា ២៨:១-២:

> «ប្រសិនបើអ្នកខំប្រឹងស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ាជាព្រះរបស់អ្នកឲ្យអស់ពីចិត្ត ព្រមទាំងប្រយ័ត្ននឹងប្រព្រឹត្តតាមអស់ទាំងបទបញ្ជាដែលខ្ញុំបង្គាប់អ្នកនៅថ្ងៃនេះ នោះព្រះយេហូវ៉ាជាព្រះរបស់អ្នកនឹងលើកអ្នកឡើងជាខ្ពស់ លើអស់ទាំងសាសន៍នៅលើផែនដី។ ព្រះពរទាំងអស់នេះនឹងធ្លាក់មកលើអ្នក ហើយតាមអ្នកជាប់ ប្រសិនបើអ្នកស្តាប់តាមព្រះសូរសៀងរបស់ព្រះយេហូវ៉ាជាព្រះរបស់អ្នក»។

នោះជាលក្ខខណ្ឌដែលនៅតែបន្តជាប់ជានិច្ច។ នោះជារបៀបដែលយើងត្រូវរស់នៅ។ កាលបើយើងត្រូវបានប្រោសលោះចេញពីបណ្តាសា ហើយបានចូលទៅក្នុងព្រះពរនោះហើយ ដើម្បីឲ្យបន្តនៅជាប់ក្នុងព្រះពរ យើងត្រូវបំពេញលក្ខខណ្ឌដ៏សាមញ្ញទាំងនេះ គឺយើងត្រូវយកចិត្តទុកដាក់ស្តាប់ព្រះសូរសៀងរបស់ព្រះ និងធ្វើតាមអ្វីដែលព្រះអង្គមានបន្ទូល។ ប្រសិនបើយើងបែរចេញម្តងទៀត ហើយមិនព្រមស្តាប់ព្រះសូរសៀង ក៏មិនព្រមស្តាប់បង្គាប់ព្រះអង្គ នោះយើងធ្វើឲ្យខ្លួនឯងត្រូវបណ្តាសាដោយស្វ័យប្រវត្តិសាជាថ្មីម្តងទៀត។

លក្ខខណ្ឌនេះមិនមែនជារបស់ការពារឲ្យរួចពីបណ្តាសាទេ។ លក្ខខណ្ឌនេះគឺជាលក្ខខណ្ឌសាកលដើម្បីឲ្យមានព្រះគុណរបស់ព្រះ ដើម្បីឲ្យមានពន្លឺនៃព្រះភក្ត្ររបស់ព្រះអង្គចែងចាំងមកលើយើង ដោយរស់នៅក្នុងសេចក្តីសង្គ្រោះ ព្រះពរ និងការផ្គត់ផ្គង់របស់ព្រះអង្គ។ ព្រះយេស៊ូវបានបន្ទូលដូចគ្នាសម្រាប់អស់អ្នកដែលចង់ដើរតាមព្រះអង្គ និងបម្រើព្រះអង្គ ក្នុងនាមជាគ្រីស្តបរិស័ទ និងជាសិស្ស។ នៅក្នុងយ៉ូហាន ១០:២៧ ព្រះអង្គបានបញ្ជាក់ពីគោលការណ៍ដដែល តាមភាសាយ៉ាងសាមញ្ញ។ ព្រះអង្គបានមានបន្ទូលថា:

> «ចៀមរបស់ខ្ញុំតែងស្តាប់សំឡេងខ្ញុំ ខ្ញុំស្គាល់ចៀមទាំងនោះដែរ ហើយចៀមទាំងនោះមកតាមខ្ញុំ»។

តើលក្ខខណ្ឌគ្រឹះសម្រាប់គ្រីស្តបរិស័ទជាអ្វី? លក្ខខណ្ឌនោះមិនមែនវិហារដែលលោកអ្នកទៅថ្វាយបង្គំ ក៏មិនមែនជាឈ្មោះនិកាយរបស់លោកអ្នកដែរ។ ទាំងអស់នោះជារឿងបន្ទាប់បន្សំ។ លក្ខខណ្ឌចម្បង គឺស្តាប់សំឡេងរបស់ព្រះយេស៊ូវ ហើយដើរតាមព្រះអង្គ។ លោកអ្នកឃើញទេ លក្ខខណ្ឌនេះមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះគម្ពីរ «ប្រសិនបើអ្នកខំប្រឹងស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ាជាព្រះរបស់អ្នកឲ្យអស់ពីចិត្ត ព្រមទាំងប្រយ័ត្ននឹងប្រព្រឹត្តអ្វីដែលត្រឹមត្រូវនៅព្រះនេត្រព្រះយេហូវ៉ា នោះព្រះពរទាំងអស់នេះនឹងធ្លាក់មកលើអ្នក»។ «ចៀមរបស់ខ្ញុំតែងស្តាប់សំឡេងខ្ញុំ ហើយចៀមទាំងនោះមកតាមខ្ញុំ»។ លោកអ្នកមិនអាចគេចចេញពីលក្ខខណ្ឌគ្រឹះនេះបានទេ។ លក្ខខណ្ឌគ្រឹះនេះបានទេ។ អ្វីដែលខ្ញុំអាចជួយលោកអ្នកឲ្យធ្វើបាន គឺចេញពីក្រោមបណ្តាសានោះមក ហើយ ថ្វាយខ្លួនលោកអ្នកយ៉ាងប្តូរផ្តាច់ចំពោះព្រះគុណរបស់ព្រះទៅ។ ក្រោយនោះមក លោកអ្នកមានការទទួលខុស ត្រូវដើម្បីរស់នៅក្នុងជីវិតមួយដែលលោកអ្នកបន្តនៅក្នុងព្រះគុណរបស់ព្រះ បន្តនៅក្នុងព្រះពររបស់ព្រះអង្គ តទៅទៀត។

ដើម្បីចូលទៅក្នុងព្រះពរ ហើយចេញពីក្រោមបណ្តាសា យើងត្រូវចេញពីអ្វីដែលខ្ញុំហៅថា ពី ច្បាប់» ទៅកាន់ «បទពិសោធន៍»។ ព្រះយេស៊ូវបានប្រទានការផ្គត់ផ្គង់នេះរួចហើយ។ ការនោះបានកើតឡើង តាំងពី ជាង២០សតវត្សរ៍មុនម្លេះ។ នៅលើឈើឆ្កាង ព្រះយេស៊ូវបានត្រឡប់ជាត្រូវបណ្តាសា ដើម្បីឲ្យយើងទទួលបានព្រះពរ។ ការនោះប្រទានឲ្យរួចហើយ ប៉ុន្តែយើងត្រូវធ្វើឲ្យការនោះត្រឡប់ជាពិត នៅក្នុងបទពិសោធន៍ផ្ទាល់ ខ្លួនរបស់យើង។

គ្រប់ផ្នែកនៃអ្វីដែលព្រះយេស៊ូវបានធ្វើនៅលើឈើឆ្កាងក៏យ៉ាងដូច្នោះដែរ។ ព្រះអង្គទទួលទោស ដើម្បីឲ្យ យើងទទួលបានការអត់ទោស។ ព្រះអង្គបានរងរបួស ដើម្បីឲ្យយើងបានជា។ ការទាំងអស់នេះ បានសម្រេចរួច ហើយ។ ប៉ុន្តែ ដើម្បីទទួលបានការអត់ទោស យើងត្រូវធ្វើអ្វីដែលព្រះទ្រង់តម្រូវ។ ដើម្បីទទួលបានការប្រោស ឲ្យជា យើងត្រូវធ្វើអ្វីដែលព្រះទ្រង់តម្រូវ ហើយជាមួយនឹងការផ្គត់ផ្គង់នេះ ក៏យ៉ាងដូច្នោះដែរ។ ព្រះយេស៊ូវបាន ត្រឡប់ជាត្រូវបណ្តាសា ដើម្បីឲ្យយើងទទួលបានព្រះពរ។ ការនោះបានសម្រេចរួចហើយ មិនចាំបាច់សម្រេចម្តង ទៀតទេ ប៉ុន្តែយើងត្រូវទទួលយកការផ្គត់ផ្គង់នេះនៅក្នុងជីវិតខ្លួនយើងផ្ទាល់ ហើយជាអ្វីដែលខ្ញុំហៅថា «ចេញ ពីច្បាប់ ទៅកាន់បទពិសោធន៍ពិត»។ ដើម្បីមានបទពិសោធន៍ផ្ទាល់ខ្លួនក្នុងករណីបណ្តាសា យើងត្រូវស្គាល់ ច្បាស់អំពីបុព្វហេតុ ឬប្រភពរបស់បណ្តាសា។ ដូច្នេះហើយបានជាខ្ញុំចំណាយពេលយ៉ាងច្រើននៅក្នុងមេរៀនទាំង នេះ និយាយអំពីបុព្វហេតុ ឬប្រភពផ្សេងៗរបស់បណ្តាសា។

នៅពេលដែលយើងស្គាល់បុព្វហេតុ ស្គាល់ប្រភព ពេលវេលាជាក់លាក់ និងបទពិសោធន៍ដែលធ្វើឲ្យ យើង (ឬបុព្វបុរស ឬអ្នកដទៃទៀតដែលមានទំនាក់ទំនងជាមួយយើង) ត្រូវបណ្តាសានោះ នោះមានការបួន ដែលយើងត្រូវធ្វើ។ ការទាំងបួននោះមាន: ទទួលស្គាល់ ប្រែចិត្ត ប្រកាសកាត់ផ្តាច់ តយុទ្ធ។

ទទួលស្គាល់: យើងទទួលស្គាល់បញ្ហារបស់យើង និងប្រភពរបស់វា។

ប្រែចិត្ត: យើងត្រូវប្រែចិត្តចេញពីអ្វីក៏ដោយដែលធ្វើឲ្យយើងជួបបញ្ហានោះ ទោះជាអំពើបាបរបស់ខ្លួនយើងផ្ទាល់ ឬអំពើបាបរបស់ដូនតាយើង។

ប្រកាសកាត់ផ្តាច់: យើងត្រូវនិយាយថា «បណ្តាសានេះមិនមែនជារបស់ខ្ញុំទៀតទេ។ ខ្ញុំមិនទទួលយកបណ្តាសានេះឡើយ។ តាមរយៈព្រះយេស៊ូវ ខ្ញុំមានសិទ្ធិរួចផុតពីបណ្តាសានេះ។ វាមិនមែនជាបញ្ហារបស់ខ្ញុំទៀតទេ»។

តយុទ្ធ: យើងត្រូវក្រោកឈរឡើងធ្វើសកម្មភាពតយុទ្ធនឹងអំណាចរបស់អារក្សសាតាំង។

ខ្ញុំសូមបញ្ជាក់ពាក្យទាំងបួននេះម្តងទៀត ទទួលស្គាល់ ប្រែចិត្ត ប្រកាសកាត់ផ្តាច់ តយុទ្ធ។

ខ្ញុំសូមជូនបទគម្ពីរមួយដល់លោកអ្នក នៅយ៉ាកុប ៤:៧ និយាយអំពីការប្រឆាំងនឹងអារក្សសាតាំង។ នេះជាកិច្ចការមួយក្នុងចំណោមកិច្ចការដែលព្រះគម្ពីរប្រាប់ថា យើងត្រូវតែធ្វើ «ដូច្នេះ សូមចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាមិនខាន»។ សូមកត់សម្គាល់ពីលំដាប់លំដោយ។ តើ កិច្ចការទីមួយដែលយើងត្រូវធ្វើជាអ្វី? ចុះចូលចំពោះព្រះ។ បន្ទាប់មក នៅពេលដែលយើងធ្វើបែបនោះហើយ យើងអាចតស៊ូនឹងអារក្សសាតាំងបាន ហើយព្រះគម្ពីរប្រាប់ថា វានឹងរត់ចេញពីយើង។ តើលោកអ្នកជឿការនេះ ឬទេ? ខ្ញុំប្រាប់លោកអ្នកថា ខ្ញុំជឿការនេះ ដោយព្រោះហេតុផលពីរៈ ទីមួយ ដោយព្រោះព្រះគម្ពីរប្រាប់យើងថា ដូច្នោះ ។ ហើយទីពីរ ដោយព្រោះខ្ញុំបានឃើញថាវាជាការពិតនៅក្នុងបទពិសោធន៍របស់ខ្ញុំផ្ទាល់។ នៅពេលដែលខ្ញុំបាន ចុះចូលចំពោះព្រះ ហើយដោយផ្អែកលើមូលដ្ឋានគ្រឹះនៃបទគម្ពីរ ខ្ញុំតយុទ្ធនឹងអារក្ស នោះវានឹងរត់ចេញពីខ្ញុំ។

ឥឡូវនេះ ដើម្បីឱ្យរឿងនេះកើតឡើងពិតប្រាកដនៅក្នុងជីវិតរបស់យើង យើងចាំបាច់ត្រូវអធិស្ឋាននូវសេចក្តីអធិស្ឋានមួយដែលបំពេញតាមលក្ខខណ្ឌតម្រូវរបស់ព្រះ។ដោយសារពេលវេលារបស់យើងសម្រាប់ថ្ងៃនេះបានអស់ហើយ ខ្ញុំសូមបញ្ចប់ការអធិប្បាយត្រឹមប៉ុណ្ណេះសិន។ ប៉ុន្តែខ្ញុំនឹងត្រឡប់មកជួបបងប្អូនម្តងទៀតនៅថ្ងៃស្អែក ក្នុងម៉ោងដដែលនេះ។នៅថ្ងៃស្អែក ខ្ញុំនឹងចែករំលែកជាមួយបងប្អូនអំពីទម្រង់នៃសេចក្តីអធិស្ឋានយ៉ាងច្បាស់លាស់ ដែលបងប្អូនចាំបាច់ត្រូវអធិស្ឋាន។ ដូច្នេះ សូមបងប្អូនកុំខកខានក្នុងការស្តាប់កម្មវិធីម្តងទៀតនៅថ្ងៃស្អែក មិនថាមានរឿងអ្វីកើតឡើងក៏ដោយ ព្រោះខ្ញុំនឹងប្រគល់កូនសោមួយទៅក្នុងដៃរបស់បងប្អូន ដែលអាចបើកទ្វារគុកដែលកំពុងឃុំឃាំងបងប្អូន ហើយដោះលែងបងប្អូនឱ្យមានសេរីភាពវិញ។

ផតខាស
ប្រតិចារិក: RP-R139-103-KHM
បច្ចុប្បន្នភាពចុងក្រោយ: 16 Nov 2026
គេហទំព័រ: Derekprince.com/km/resources

